# មណ្ឌលសិក្សាធិការយូនីហ្វៃដ៍អូកឡិនដ៍ បង្ហាញថា
# មគ្គុទ្ទេសក៍ស្តង់ដារមុខវិជ្ជាស្នូលរួមសម្រាប់មាតាបិតាក្នុងនាមជាដៃគូ ថ្នាក់ទី 4

មណ្ឌលសិក្សាធិការយូនីហ្វៃដ៍អូកឡិនដ៍ ជឿទៅលើសំណុំមួយនៃជំនឿស្នូលអំពីគ្រួសារដែលយើងបម្រើជូនជារៀងរាល់ថ្ងៃ។

**ជំនឿគោល #1** មាតាបិតាទាំងអស់មានក្តីស្រមៃសម្រាប់កូនរបស់ខ្លួន និងចង់ឲ្យពួកគេល្អ
**ជំនឿគោល #2** ភាពជាដៃគូរជាមួយគ្រួសារគឺមានសារសំខាន់ចំពោះសមិទ្ធិផលនៃការសិក្សា
**ជំនឿគោល #3** មាតាបិតាទាំងអស់អាចគាំទ្រការសិក្សារបស់កូនរបស់ពួកគេបាន
**ជំនឿគោល #4** ការទទួលខុសត្រូវក្នុងការបង្កើតភាពជាដៃគូរវាងសាលា និងផ្ទះ ផ្អែកជាចំបងលើបុគ្គលិកសាលា ជាពិសេសថ្នាក់ដឹកនាំសាលា។

ពីព្រោះយើងប្រកាន់យកនូវជំនឿគោលលើការចូលរួមរបស់គ្រួសារ យើងបានបង្កើតសម្ភារ និងធនធានដើម្បីធានាថា គ្រួសារទាំងអស់យល់អំពី**ស្តង់ដារមុខវិជ្ជាស្នូល** និងអាចគាំទ្រការសិក្សានៅក្នុងផ្ទះ។ ធនធានទាំងនេះរួមមាន កញ្ចប់នៃសៀវភៅសម្រាប់មុខវិជ្ជាគោលទាំងអស់ (*Common Core Backpack*) ដែលទាំងនោះគឺជាសកម្មភាពដែលមាតាបិតាអាចប្រើនៅផ្ទះ ដើម្បីពង្រឹងស្តង់ដារនៃមុខវិជ្ជាគោលទាំងនោះ។

| តើអ្វីគឺស្តង់ដារមុខវិជ្ជាស្នូល? | ហេតុអ្វីត្រូវការមុខវិជ្ជាស្នូល |
|---|---|
| កាលពីមុន រដ្ឋនិមួយៗមានកម្រិតស្តង់ដារអប់រំរបស់ខ្លួន។ ចំណុចនេះបានបង្កឲ្យមានការភាន់ច្រលំ និងក្តីបារម្មណ៍អំពីថាតើសិស្សរបស់យើងត្រៀមខ្លួនសម្រាប់ចូល មហាវិទ្យាល័យ និងអាជីពការងារនៅក្នុងពេលបញ្ចប់ការសិក្សាពីវិទ្យាល័យ ឬអត់។ រដ្ឋ កាលីហ្វ័រញ៉ា បានអនុម័តនូវស្តង់ដារមុខវិជ្ជាស្នូលនៅក្នុងឆ្នាំ 2010។<br><br>ស្តង់ដារមុខវិជ្ជាស្នូលរបស់រដ្ឋ (CCSS) គឺជាការរំពឹងទុកនៃការសិក្សាមួយនៅក្នុងសិល្បៈភាសាអង់គ្លេស និងគណិតវិទ្យា ដែលបានបង្កើតឡើងដើម្បីត្រៀមសិស្សថ្នាក់ទី12 (K-12) ឲ្យចូលរៀនមហាវិទ្យាល័យ និងជោគជ័យអាជីពការងារ។ CCSS បង្ហាញឲ្យដឹងអំពីអ្វីដែលត្រូវបានរំពឹងពីសិស្ស នៅតាមកម្រិតនិមួយៗ ដោយឲ្យសិស្ស មាតាបិតា គ្រូបង្រៀន និងអ្នកគ្រប់គ្រងសាលា ស្ថិតនៅក្នុងទីតាំងតែមួយដូចគ្នា ខណៈពេលកំពុងធ្វើការឆ្ពោះទៅរកគោលដៅរួមគ្នា។ | ស្តង់ដារមុខវិជ្ជាស្នូលរបស់រដ្ឋគឺមានសារសំខាន់ពីព្រោះមុខវិជ្ជាទាំងនេះនឹងជួយកុមារទាំងអស់ មិនថាពួកគេជានរណានោះទេ សុទ្ធតែរៀនជំនាញដូចគ្នាសម្រាប់ត្រៀមចូល មហាវិទ្យាល័យ និងអាជីពការងារ។ ពួកគេបង្កើតការរំពឹងទុកច្បាស់លាស់មួយសម្រាប់ អ្វីដែលកូនរបស់អ្នកគួរដឹង និងអាចធ្វើ នៅក្នុងផ្នែកសំខាន់ផ្សេងៗ៖ អក្ខរកម្ម (**ការអាន សរសេរ និយាយ** និង**ស្តាប់**លើគ្រប់ផ្នែកនៃមុខវិជ្ជា) និង**គណិតវិទ្យា**។<br><br>ប្រសិនអ្នកដឹងការរំពឹងទុកទាំងនោះគឺជាអ្វី ក្រោយមកអ្នកអាចជួយកូនរបស់អ្នករៀបចំខ្លួន ពីព្រោះលោកអ្នកគឺជាគ្រូដំបូងរបស់កូនលោកអ្នក។<br><br>សិស្សរបស់យើងគឺជាអ្នកវិទ្យាសាស្ត្រ អ្នកស្រាវជ្រាវ អ្នកគ្រប់គ្រង និងអ្នករចនាប្លង់នាពេលអនាគត។ ពួកគេគឺជាអ្នកដោះស្រាយបញ្ហា និងសហការ។ មុខវិជ្ជាស្នូលត្រៀម ធ្វើឲ្យពួកគេប្រកួតប្រជែងជាមួយ មិនមែនត្រឹមតែមិត្តភ័ក្រ្តជនជាតិអាមេរិកកាំងនៅក្នុងរដ្ឋផ្សេងទៀតប៉ុណ្ណោះទេ ប៉ុន្តែជាមួយសិស្សដែលមកពីបណ្តាប្រទេសនានាលើពិភពលោក។ |

## តើគ្រួសារអាចគាំទ្រជោគជ័យរបស់សាលាដោយរបៀបណា?

ភាពជាដៃគូរជាមួយគ្រួសារគឺមានសារសំខាន់សម្រាប់ជោគជ័យនៃការសិក្សា។ និយាយយ៉ាងសាមញ្ញ សាលាមិនអាចអប់រំសិស្សតែម្នាក់ឯងបានទេ។ តើគ្រួសារអាចធ្វើជាដៃគូជាមួយ សាលាបានដោយរបៀបណា?

1. ដឹងពីអ្វីដែលកូនរបស់អ្នកគួររៀននៅថ្នាក់ទី 4
2. សួរគ្រូថាតើកូនរបស់អ្នកមានទទួលជំនាញដែលបានបង្រៀនហើយឬនៅ
3. សួរថាតើលោកអ្នកអាចគាំទ្រការសិក្សានៅផ្ទះដោយរបៀបណា។ សួររកសកម្មភាពពីកញ្ចប់នៃសៀវភៅសម្រាប់មុខវិជ្ជាគោលទាំងអស់ *(Common Core Backpack)* ដែលគឺជាសកម្មភាព ដែលមាតាបិតាប្រើនៅផ្ទះជាមួយកូន ដើម្បីទទួលបានចំណេះដឹងពីស្តង់ដារមុខវិជ្ជាស្នូលទាំងនោះ។
4. អាន អាន អាន។ សូមឲ្យកូនរបស់លោកអ្នកអានជារៀងរាល់ថ្ងៃ និងសួរសំណួរទៅពួកគេ។ ក្រោយមកទៀត ឲ្យពួកគេទៅអានអត្ថបទដើម្បីឆ្លើយសំណួរ "តើអ្នកដឹងដោយរបៀបណា?
5. ត្រូវប្រាកដថា កូនរបស់លោកអ្នកគឺកំពុងអានសៀវភៅដែលមិនមែនជាប្រលោមលោកប្រឌិត ជាញឹកញាប់។

# ស្តង់ដារមុខវិជ្ជាស្នូលរួមសម្រាប់ថ្នាក់ទី 4

នេះគឺជាបំណិន **<u>សិល្បៈភាសាអង់គ្លេស</u>** សំខាន់មួយចំនួនដែលត្រូវយកមកបង្រៀននៅក្នុងថ្នាក់ទី4។ សម្រាប់តារាងស្តង់ដារមុខវិជ្ជាស្នូលរដ្ឋកាលីហ្វ័រញ៉ា សូមចូលទៅគេហទំព័រក្រសួងអប់រំរដ្ឋកាលីហ្វ័រញ៉ា (http://www.cde.ca.gov/re/cc/)។
មានសកម្មភាពពីកញ្ចប់នៃសៀវភៅសម្រាប់មុខវិជ្ជាគោល សម្រាប់ស្តង់ដារមុខវិជ្ជាស្នូលនិមួយដែលមានរៀបរាប់ក្នុងបញ្ជីខាងក្រោម៖

| ស្តង់ដារមុខវិជ្ជាស្នូលរួម | | ជាទូទៅ វាមានន័យថា កូនរបស់អ្នកអាច... |
|---|---|---|
| RL.4.1 | ផ្អែកលើព័ត៌មានលម្អិត និងឧទាហរណ៍ក្នុងអត្ថបទនៅពេលធ្វើការពន្យល់អំពីគំនិតបង្ហាញត្រង់របស់អត្ថបទ និងនៅពេលទាញសេចក្តីសន្និដ្ឋានពីអត្ថបទ។ | ពន្យល់ពីសាច់រឿងដោយផ្អែកលើព័ត៌មានលម្អិត និងឧទាហរណ៍នៅក្នុងអត្ថបទ។ |
| RL.4.2 | កំណត់ពីមូលបទនៅក្នុងរឿង ល្ខោន ឬកំណាព្យចេញពីព័ត៌មានលម្អិតនៅក្នុងអត្ថបទ សង្ខេបអត្ថបទ។ | សង្ខេបប្រឌិតកថាមួយដោយប្រើប្រាស់ពាក្យរបស់ខ្លួន។ |
| RL.4.3 | ពណ៌នាដោយល្អិតល្អន់អំពីតួអង្គ ទស្សនីយភាព ឬព្រឹត្តិការណ៍ក្នុងរឿង ឬល្ខោន ដោយប្រើប្រាស់ព័ត៌មានលម្អិតជាក់លាក់ក្នុងអត្ថបទ (ឧទាហរណ៍ គំនិត ពាក្យពេចន៍ ឬសកម្មភាពរបស់តួអង្គណាម្នាក់)។ | ប្រើប្រាស់ព័ត៌មានលម្អិតជាក់លាក់នៅក្នុងអត្ថបទដើម្បីជំនួយក្នុងការពណ៌នាតួអង្គ ទស្សនីយភាព ឬព្រឹត្តិការណ៍នៅក្នុងរឿង។ |
| RL.4.4 | កំណត់អត្ថន័យនៃពាក្យ និងឃ្លាដែលត្រូវបានប្រើប្រាស់នៅក្នុងអត្ថបទ រួមទាំងពាក្យ និងឃ្លាដែលពណ៌នាបញ្ជិតបញ្ជៀងលើតួអង្គសំខាន់ៗដែលមាននៅក្នុងទេវកថា (ឧទាហរណ៍៖ រឹងប៉ឹងមាំមួន [Herculean]) ។ | កំណត់អត្ថន័យនៃពាក្យ និងឃ្លាដែលអ្នកនិពន្ធប្រើប្រាស់។ |
| RL.4.5 | ពន្យល់ពីភាពខុសគ្នាសំខាន់ៗរវាង កំណាព្យ ល្ខោន និងអត្ថបទពាក្យរាយ និងសិក្សាអំពីរចនាសម្ព័ន្ធធាតុផ្សំនៃកំណាព្យ (ឧទាហរណ៍ ឃ្លា ពាក្យចួន និងវង្វាស់) និងល្ខោន (ឧទាហរណ៍ តួអង្គ ទស្សនីយភាព ការពិពណ៌នា ការសន្ទនា និងឈុតសម្តែង) នៅពេលសរសេរ ឬនិយាយអំពីអត្ថបទ។ | ផ្អែកលើធាតុផ្សំជាក់លាក់នៃកំណាព្យ (ឃ្លា ពាក្យចួន និងវង្វាស់) និងល្ខោន (តួអង្គ ទស្សនីយភាព ការពណ៌នា ការសន្ទនា និងឈុតសម្តែង) នៅពេលគាត់សរសេរ ឬនិយាយអំពីប្រឌិតកថាមួយ។ |
| RL.4.7 | ធ្វើឲ្យមានទំនាក់ទំនងរវាងអត្ថបទនៅក្នុងរឿង ឬល្ខោនមួយ និងធ្វើបទបង្ហាញដោយប្រើប្រាស់រូបភាព ឬនិទានអំពីអត្ថបទ កំណត់អំពីទីកន្លែងដែលឃ្លានិមួយៗឆ្លុះបញ្ចាំងអំពីការពណ៌នាជាក់លាក់ និងឈុតនៅក្នុងអត្ថបទ។ | ធ្វើឲ្យមានទំនាក់ទំនងរវាងអត្ថបទដែលបានសរសេរ និងការបកស្រាយលម្អិតនៃអត្ថបទដូចគ្នា។ |
| RI.4.1 | សួរ និងឆ្លើយសំណួរអំពីព័ត៌មានលម្អិតសំខាន់នៅក្នុងអត្ថបទ។ | ពន្យល់អំពីការបង្រៀនរឿងប្រលោមលោកមិនប្រឌិតមួយ ដោយផ្អែកលើព័ត៌មានលម្អិត និងឧទាហរណ៍នៅក្នុងអត្ថបទ។ |
| RI.4.2 | កំណត់អំពីប្រធានបទសំខាន់ និងនិទានឡើងវិញនូវព័ត៌មានលម្អិតសំខាន់ៗនៅក្នុងអត្ថបទមួយ។ | កំណត់ពីគំនិតសំខាន់នៅក្នុងរឿងប្រលោមលោកមិនប្រឌិតមួយ ដោយប្រើប្រាស់ព័ត៌មានលម្អិតសំខាន់ៗនៅក្នុងអត្ថបទ។ |
| RI.4.2 | កំណត់អំពីប្រធានបទសំខាន់ និងនិទានឡើងវិញនូវព័ត៌មានលម្អិតសំខាន់ៗនៅក្នុងអត្ថបទមួយ។ | សង្ខេបរឿងប្រលោមលោកមិនប្រឌិតមួយ។ |
| RI.4.7 | ប្រើប្រាស់រូបភាព និងព័ត៌មានលម្អិតនៅក្នុងអត្ថបទដើម្បីពណ៌នាអំពីគំនិតសំខាន់។ | បកស្រាយ និងប្រើប្រាស់ព័ត៌មានពីតារាង ក្រាហ្វ ដ្យាក្រាម បន្ទាត់ពេលវេលា គំនូរជីវចល ឬការបង្ហាញតាមប្រព័ន្ធអ៊ីនធើណិតដើម្បីយល់អំពីរឿងប្រលោមលោកមិនប្រឌិតមួយ។ |
| RF.4.4 | អានបានយ៉ាងត្រឹមត្រូវ និងស្ទាត់ជំនាញគ្រប់គ្រាន់ ដើម្បីគាំទ្រដល់ការយល់ដឹង។<br>a. អានអត្ថបទតាមលំដាប់ថ្នាក់ដោយមានគោលបំណង និងការយល់ដឹង។<br>b. អានពាក្យរាយ និងពាក្យកាព្យតាមលំដាប់ថ្នាក់ដោយផ្ទាល់មាត់មានអត្រាត្រឹមត្រូវ និងសំនួនវោហារស័ព្ទអំពីអំណានបន្តបន្ទាប់គ្នា។<br>c. ប្រើបរិបទដើម្បីបញ្ជាក់អះអាង ឬស្វ័យកែតម្រូវការស្គាល់ការយល់ និងការអានពាក្យណាមួយឡើងវិញតាមការចាំបាច់។ | ប្រើប្រាស់បរិបទដើម្បីបញ្ជាក់ពីការយល់អត្ថបទថ្នាក់ទីបួន និងអានម្តងទៀតតាមការចាំបាច់ ។ |

*ស្តង់ដារដែលមានភាពងាយស្រួលសម្រាប់មាតាបិតា ដែលដកស្រង់ពីលោក Jill និង Cathey Henry។ "I Can Standards." www.thecurricculumcorner.com. ថ្ងៃទី 3 ខែធ្នូ ឆ្នាំ 2012*

# ស្តង់ដារមុខវិជ្ជាស្នូលរួមសម្រាប់ថ្នាក់ទី 4

ទាំងនេះគឺជាបំណិន **គណិតវិទ្យា** សំខាន់ៗដែលកំពុងត្រូវបានបង្រៀននៅថ្នាក់ទី 4។ សម្រាប់បញ្ជីទាំងស្រុងស្តីពីស្តង់ដារមុខវិជ្ជាស្នូលរួមរបស់រដ្ឋកាលីហ្វ័រញ៉ា សូមមើលវិបសាយរបស់ក្រសួងអប់រំរដ្ឋកាលីហ្វ័រញ៉ា (http://www.cde.ca.gov/re/cc/)។

មានសកម្មភាពកញ្ចប់នៃសៀវភៅសម្រាប់មុខវិជ្ជាគោលសម្រាប់ស្តង់ដារមុខវិជ្ជាស្នូលរួមនីមួយៗ ដូចមានរាយឈ្មោះនៅខាងក្រោម។

| ស្តង់ដារមុខវិជ្ជាស្នូលរួម | | ជាទូទៅ វាមានន័យថា កូនរបស់អ្នកអាច... |
|---|---|---|
| 4.OA.1 | បកស្រាយសមីការវិធីគុណដោយការប្រៀបធៀប។ ឧទាហរណ៍ បកស្រាយ 35 = 5 x 7 មានន័យថា 35 គឺស្មើនឹង 5 គុណនឹង 7 ស្មើនឹង 7 គុណនឹង 5។ តាងការថ្លែងជាពាក្យពេចន៍អំពីការប្រៀបធៀបវិធីគុណជាសមីការវិធីគុណ។ | យល់ថាចំណោទនៃវិធីគុណអាចប្រើប្រាស់ជាការប្រៀបធៀបនៃក្រុម (ឧទាហរណ៍ 24 = 4 x 6 អាចកំណត់ជា 4 ក្រុមនៃ 6 ឬ 6 ក្រុមនៃ 4) ។ |
| 4.OA.2 | គុណ ឬចែកដើម្បីដោះស្រាយចំណោទពាក់ព័ន្ធនឹងការប្រៀបធៀបការគុណចំនួន។ ឧទាហរណ៍ ដោយប្រើប្រាស់គំនូសតាង និងសមីការរួមនឹងនិមិត្តសញ្ញាសម្រាប់តំណាងឲ្យចំនួនដែលមិនស្គាល់នៅក្នុងចំណោទ បង្ហាញពីភាពខុសគ្នានៃការប្រៀបធៀបការគុណចំនួន និងការបូកចំនួន។1 | គុណ ឬចែកដើម្បីដោះស្រាយចំណោទដោយប្រើប្រាស់គំនូសតាង ឬសរសេរសមីការ និងកំណត់តម្លៃលេខដែលបាត់។ |
| 4.OA.3 | ដោះស្រាយចំណោទដែលមានច្រើនដំណាក់កាលជាមួយនឹងចំនួនគត់ និងផ្តល់ចម្លើយជាចំនួនគត់ដោយប្រើប្រាស់ការគណនាបួន រួមទាំងចំណោទដែលត្រូវបកស្រាយពីសំណល់។ តាងចំណោទទាំងនេះដោយប្រើប្រាស់សមីការដែលមានអក្សរតំណាងអញ្ញាតនៃចំនួនដែលមិនស្គាល់។ វាយតម្លៃលក្ខណៈសមហេតុផលនៃចម្លើយដោយប្រើប្រាស់ការគណនាក្នុងខួរក្បាល និងយុទ្ធសាស្ត្រនៃការប៉ាន់ស្មាន រួមទាំងការបង្គត់ចំនួន។ | ប្រើប្រាស់ចំណេះដឹងពីវិធីបូក ដក គុណ និងចែកដើម្បីដោះស្រាយចំណោទដែលមានច្រើនដំណាក់កាលពាក់ព័ន្ធនឹងចំនួនគត់។ |
| 4.NBT.2 | អាន និងសរសេរចំនួនគត់ច្រើនខ្ទង់ដោយប្រើប្រាស់លេខ 10 ខ្ទង់នៃលេខ និងទម្រង់ពន្លាត។ ប្រៀបធៀបលេខពីរខ្ទង់ផ្អែកលើអត្ថន័យនៃខ្ទង់ក្នុងតម្លៃនិមួយៗ ដោយប្រើសញ្ញា >, =, និង < ដើម្បីកត់ត្រាលទ្ធផលនៃការប្រៀបធៀប។ | អាន និងសរសេរចំនួនគត់ធំៗ ដោយប្រើប្រាស់លេខ អក្សរ និងទម្រង់ពន្លាត។ |
| 4.NBT.2 | អាន និងសរសេរចំនួនគត់ច្រើនខ្ទង់ដោយប្រើប្រាស់លេខ 10 ខ្ទង់នៃលេខ និងទម្រង់ពន្លាត។ ប្រៀបធៀបលេខពីរខ្ទង់ផ្អែកលើអត្ថន័យនៃខ្ទង់ក្នុងតម្លៃនិមួយៗ ដោយប្រើប្រាស់សញ្ញា >, =, និង < ដើម្បីកត់ត្រាលទ្ធផលនៃការប្រៀបធៀប។ | ប្រៀបធៀបចំនួនធំពីរដោយប្រើប្រាស់សញ្ញាបង្ហាញពីការប្រៀបធៀប។ |
| 4.NBT.3 | ប្រើប្រាស់ចំណេះដឹងពីតម្លៃជាក់លាក់ដើម្បីបង្គត់ចំនួនគត់ដែលមានច្រើនខ្ទង់ទៅកាន់ខ្ទង់ណាមួយក៏បាន។ | បង្គត់ចំនួនគត់ធំៗទៅកាន់ខ្ទង់ណាមួយក៏បាន។ |
| 4.NBT.4 | មានភាពស្ទាត់ជំនាញក្នុងការបូក និងដកចំនួនគត់ដែលមានច្រើនខ្ទង់ដោយប្រើប្រាស់វិធីគណនាស្តង់ដា។ | បូក និងដកចំនួនលេខធំៗ។ |
| 4.NBT.5 | គុណចំនួនគត់ដែលមានរហូតដល់បួនខ្ទង់ ជាមួយនឹងចំនួនគត់មួយខ្ទង់ និងគុណចំនួនគត់ពីរខ្ទង់ និងពីរខ្ទង់ ដោយប្រើប្រាស់យុទ្ធសាស្ត្រផ្អែកលើតម្លៃដែលបានកំណត់ និងវិធីសាស្ត្រនៃការគណនា។ ស្រាយបញ្ជាក់ និងបង្ហាញពីរបៀបគណនាដោយប្រើប្រាស់សមីការ ប្រអប់ចតុកោណកែង និងគំរូក្រលាផ្ទៃ។ | គុណចំនួនគត់រហូតដល់បួនខ្ទង់ និងចំនួនគត់មួយខ្ទង់។ |
| 4.NBT.5 | គុណចំនួនគត់ដែលមានរហូតដល់បួនខ្ទង់ ជាមួយនឹងចំនួនគត់មួយខ្ទង់ និងគុណចំនួនគត់ពីរខ្ទង់ និងពីរខ្ទង់ ដោយប្រើប្រាស់យុទ្ធសាស្ត្រផ្អែកលើតម្លៃដែលបានកំណត់ និងវិធីសាស្ត្រនៃការគណនា។ ស្រាយបញ្ជាក់ និងបង្ហាញពីរបៀបគណនាដោយប្រើប្រាស់សមីការ ប្រអប់ចតុកោណកែង និងគំរូក្រលាផ្ទៃ។ | គុណចំនួនដែលមានលេខពីរខ្ទង់ចំនួនពីរ។ |
| 4.MD.3 | ប្រើប្រាស់រូបមន្តផ្ទៃក្រលា និងបរិមាត្រចតុកោណកែងនៅក្នុងជីវភាពជាក់ស្តែង និងចំណោទគណិតវិទ្យា។ ឧទាហរណ៍ គណនាប្រវែងទទឹងរបស់បន្ទប់មួយរាងចតុកោណកែងដែលស្គាល់ពីផ្ទៃក្រលា និងប្រវែងបណ្តោយ ដោយប្រើប្រាស់រូបមន្តផ្ទៃក្រលាជាផលគុណនៃសមីការជាមួយនឹងប្រវែងដែលមិនស្គាល់។ | ប្រើប្រាស់ចំណេះដឹងអំពីផ្ទៃក្រលា និងបរិមាត្រដើម្បីដោះស្រាយចំណោទអំពីជីវភាពជាក់ស្តែងពាក់ព័ន្ធនឹងចតុកោណកែង។ |
| 4.G.1 | គូសចំណុច បន្ទាត់ កន្លះបន្ទាត់ កាំ មុំ (កែង ស្រួច ទាល) និងបន្ទាត់កែង និងបន្ទាត់ស្រប។ កំណត់ពីចំណុចទាំងនេះដោយប្រើប្រាស់រូបដែលមានវិមាត្រពីរ។ | កំណត់ និងគូសចំណុច បន្ទាត់ កន្លះបន្ទាត់ កាំ និងមុំ បន្ទាត់កែង និងបន្ទាត់ស្រប។ |